- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...១៥៤.អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម ឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើអំណោយតាមរយៈអង្គការ FIDR នូវអាគារមណ្ឌលសុខភាព ០១ ខ្នង ជូនប្រជាពលរដ្ឋក្នុងឃុំគគីរធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល មានតម្លៃជាទឹកប្រាក់ចំនួន ២២.០៣១ USD ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ...១៧៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

## សំ រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០៥ រូប ជាស្ថាបនិក អង្គការស្ពានមិត្តភាពកម្ពុជា-ហូឡង់ ដែលបានជួយកសាង និង ស្តារហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិ លើគ្រប់វិស័យពីឆ្នាំ ១៩៩១ ដល់ ឆ្នាំ ២០០១ ចំណាយអស់ថវិកាចំនួន ៦៤៥.០២៦,៥០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ÷

| | | |
|---|---|---|
| ១-លោកស្រី | **Diny Van Bruggen, M.D** | ជនជាតិហូឡង់ |
| ២-លោក | **Henk Olde** | ជនជាតិហូឡង់ |
| ៣-លោកស្រី | **Granna Olde** | ជនជាតិហូឡង់ |
| ៤-លោកសាស្ត្រាចារ្យ | **ខួន ផាន** | អង្គការស្ពានកម្ពុជា-ហូឡង់ |
| ៥-លោកគ្រូគង្វាល | **ហ៊ាន ភួយ** | អង្គការស្ពានកម្ពុជា-ហូឡង់ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១២៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តសៀមរាប

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០៥រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងខេត្តសៀមរាប ដូចមានរាយនាមខាងក្រោមនេះ ÷

| | | |
|---|---|---|
| ១ -លោក | **ស៊ាង ណារ៉េន** | កសាងផ្លូវលំក្រាលគ្រួសក្រហម នៅឃុំស្វាយដង្គំ ស្រុកសៀមរាប ថវិកា ១៦.២០០ USD |
| ២ -លោក | **ហ៊ួត ខួន** | កសាងស្ពាន ០១ កន្លែង នៅឃុំអន្លង់សំណ ស្រុកជីក្រែង ថវិកា ១៥.៤០០ USD |
| ៣-លោកស្រី | **សោម គីមសារ៉ន** | កសាងស្ពាន ០៤ កន្លែង នៅ ឃុំសៀមរាប ស្រុកសៀមរាប ថវិកា ១៣.១០០ USD |
| ៤ -ឧត្តមសេនីយ៍ត្រី | **នួន តា** | កសាងហោត្រ័យ០២ ខ្នង នៅវត្តខ្សាច់ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ថវិកា ១១.៤០០ USD |
| ៥ -លោក | **ឡាយ ស៊ីវឃី** | កសាងក្លោងទ្វារ ជំបូលខឿនព្រះវិហារវត្តខ្សាច់ ឃុំត្រពាំងធំ ស្រុកប្រាសាទបាគង ថវិកា១០.៩៥០ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ព្រះចៅអធិការវត្តវិហារបិទមាស

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ប្រគេន និង ជូនសប្បុរសជនចំនួន ១២ រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកាជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវត្តវិហារបិទមាស ឃុំព្រែកស្ដេង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ដូចមានរាយព្រះនាម និង នាមខាងក្រោម ÷

**ក_ មេដាយមាសស្ថាបនាជាតិ :**

១- ព្រះតេជគុណ **ហ៊ុន ធីម** ចៅអធិការវត្តវិហារបិទមាស បច្ច័យ ១០.២៨០ USD

២- ឯកឧត្តម **កែប ជុតិមា** ថវិកា ១០.៧៣០ USD

៣- លោកស្រី **យឹម ស៊ុនហេង** ថវិកា ១០.១៩០ USD

**ខ_ មេដាយប្រាក់ស្ថាបនាជាតិ :**

១- ឧបាសិកា **យ៉ែម សែម** ថវិកា ៥.៨៦០ USD

២- ឧបាសិកា **ស៊ុម សុខ្ខ** ថវិកា ៥.២៧០ USD

៣- លោក **គី ឡេង** ថវិកា ៥.០៧០ USD

៤- លោក **ផា តឿន** ថវិកា ៥.០៧០ USD

**គ- មេដាយសីវឌ្ឍស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១- ឧបាសិកា | **យ៉េង** | **យន** | ថវិកា | ១.៦៥០ USD |
| ២- ឧបាសិកា | **យឹម** | **លន់** | ថវិកា | ១.៤៩០ USD |
| ៣-លោក | **មួង** | **សំអាត** | ថវិកា | ១.១០០ USD |
| ៤- លោក | **ភាំង** | **សារិន** | ថវិកា | ១.២១០ USD |
| ៥- លោក | **អ៊ុង** | **ផេងគង់** | ថវិកា | ១.១១៣ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

រាជធានីភ្នំពេញ ، ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៨ សសរ

# សេចក្តីសំរេច
## ស្តីពីការអនុញ្ញាតិអោយមន្ត្រីរាជការចូលបំរើការងារវិញ

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / រកម / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ៦៧ / អនក្រ / បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២៣១ អនក្រ.កត ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងមន្ត្រីរាជការ
- សេចក្តីសំរេចលេខ ៧០ សសរ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការព្យួរការងារមន្ត្រីរាជការ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល ។

## សំរេច

**ប្រការ ១ :** ត្រូវបានអនុញ្ញាតអោយលោក **ជា គឹមឡុង** បានចូលបំរើការងារនៅកន្លែងដើមវិញ គឺជាប្រធាន

នាយកដ្ឋានថវិកានិងហិរញ្ញវត្ថុនៃក្រសួងសុខាភិបាល ក្រោយពីបានព្យួរការងារអោយនៅទំនេរគ្មានបៀវត្សរយៈពេល ០៣ ខែរួចហើយ ។

ប្រការ ២ : រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងលោក ខា គឹមឆ្លូន ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មីនា ឆ្នាំ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
  អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២២៥ សហវ

រាជធានីភ្នំពេញ ថ្ងៃទី១២ខែ មីនា ឆ្នាំ ២០០២

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតវង្វេនយ្យបុរេប្រទានទៅ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស-រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ នស/៩៤ ចុះ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស.រកម/១២០១/១៥.ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ០០៤ សហវ មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តន៍បទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ

- បានឃើញលិខិតលេខ ១១៥ សហវ. ម ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តន៍ បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញសារាចរណែនាំលេខ ០០៣ សហវ.ម ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរជ្ជទេយ្យបុរេប្រទាន
- បានឃើញប្រកាសលេខ ១២៥ ប្រក.សហវ ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៧ ស្តីពីការកំណត់ទឹកប្រាក់រជ្ជទេយ្យបុរេប្រទាន ជំពូក ១១ សំរាប់ទូទាត់ចំណាយចាំបាច់ទៅលើដំណើរការរដ្ឋបាលសំភារៈ និងការជួសជុលតូច
- បានឃើញតំរូវការចាំបាច់ នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បច្ចុប្បន្ន ។

## សំរេច

**ប្រការ ១:** ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទាន ជំពូក ១១ នៅរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ដើម្បីធ្វើការទូទាត់ចំណាយទាំងឡាយមានចែងក្នុងមាត្រា ៦៤ នៃអនុក្រឹត្យ លេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ ។ ចំនួនទឹកប្រាក់ជាអតិបរិមា នៃការចំណាយដែលអនុញ្ញាតអោយរជ្ជទេយ្យករបុរេប្រទានធ្វើការទូទាត់ត្រូវកំណត់ក្រោម ៥០០.០០០រ០០ " ប្រាំរយពាន់រៀលគត់ " តាមចំណាត់ថ្នាក់ចំណាយនិមួយៗដូចមានចែងក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយប្រកាសអន្តរក្រសួង ។

**ប្រការ ២:** ចំនួនទឹកប្រាក់ នៃរជ្ជទេយ្យបុរេប្រទាន ជំពូក ១១ សំរាប់មួយជុំនៃឆ្នាំត្រូវបានកំណត់ត្រឹម ចំនួន ២២.០៧៦.២០០រ " ម្ភៃពីរលាន ចិតសិបប្រាំមួយពាន់ ពីររយរៀលគត់ " ។

**ប្រការ ៣:** សេចក្តីសំរេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល ហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋាន ព្រមទាំងប្រធានគ្រប់អង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ មានភារកិច្ច ទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
រដ្ឋលេខាធិការ

អ៊ុក រ៉ាប៊ុន

រដ្ឋលេខាធិការ
រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

ពេជ្រ.ម៉ិនធិន

**កន្លែងទទួល :**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាប "

- ដូចប្រការ៤

" ដើម្បីមុខការ "

- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ០៩៤ MoC / M 2002

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មិនា ឆ្នាំ ២០០២

## ប្រកាស

## ស្តីពី

## ស្ថានភាពរោងចក្រកាត់ដេរ Olympic Garment Co., Ltd.,

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្របក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

## សំរេច

**ប្រការ ១ :** ចាត់ទុកថាបាន បិទទ្វារជាបណ្តោះអាសន្ន រោងចក្រកាត់ដេរសំលៀកបំពាក់ **Olympic Garment Co., Ltd.,** ដែលគ្មានសកម្មភាពចំពោះមុខដោយមានមូលហេតុផ្សេងៗ ប៉ុន្តែឧបករណ៍ផលិតកម្ម និង គ្រឿងម៉ាស៊ីននៅ រក្សាដដែលហើយកម្មករត្រូវបានបញ្ឈប់ ពីការងារជាបណ្តោះអាសន្ន។ រោងចក្រកាត់ដេរសំលៀកបំពាក់នោះនឹងត្រូវលប់ចេញពីតារាង GSP នៃអ្នកមានសិទ្ធ នាំចេញ នៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ ការបែងចែកកូតាផ្សេងៗ (បើមាន) នឹងត្រូវផ្អាក ។ រោងចក្រខាងលើនេះ អាចទទួលបានសិទ្ធនាំចេញសាជាថ្មី ប្រសិនបើ

រោងចក្រទាំងនោះបន្តសកម្មភាពរបស់ ខ្លួនវិញក្នុងរយៈពេល ៣ ខែបន្ទាប់ ហើយកូតាឆ្នាំ ២០០០ ជាមូលដ្ឋាន នឹងត្រូវបានប្រគល់ជូនវិញ ។ ប្រសិនបើរោងចក្រទាំងនោះមិនបានបន្តសកម្មភាពរបស់ខ្លួនក្នុងរយៈពេល ៣ ខែបន្ទាប់ រោងចក្រទាំងនោះនឹងត្រូវចាត់ទុកថាបានបិទទ្វារជាស្ថាពរ ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មរបស់គេនឹងត្រូវឆូត ពណ៌ក្រហម និង ចារថាបានបិទទ្វារ ។

**ប្រការ ២ :** ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវធ្វើឡើងដោយ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម, នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស, នាយកដ្ឋាននីតិកម្ម ទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតិយជន នៅកម្ពុជា ព្រមទាំងបំណុលរបស់គេ ចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាន នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននីតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

ចម្លងជូន :

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច-ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនិតិសម្បទា
- ស្ថានទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងបាងកក
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

ព្រះរាជាណាចក្រកម្ពុជា

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

**Ministry of Commerce**

No. 094 MoC / M 2002

***From the Minister's Desk***

Phnom Penh, March 12, 2002

# PRAKAS

## On The Status of Olympic Garment Co., Ltd., in Cambodia

*****

## THE MINISTER OF COMMERCE

- *Pursuant to the Constitution of the Kingdom of Cambodia;*
- *Pursuant to the Preah Reach Kram No 02/NS/94 dated July 20, 1994 on the Organization and Functioning of the Council of Ministers;*
- *Pursuant to the Royal Decree No NS/RK/1198/72 dated November 30, 1998 on the Appointment of the Royal Government of Cambodia;*
- *Pursuant to the Preah Reach Kram No SN/RK/ 0196/16 dated January 24, 1996 on the Creation of the Ministry of Commerce;*
- *Pursuant to the Sub-Decree No 54 AK dated September 22, 1997 on the Organization and Functioning of the Ministry of Commerce;*
- *Seen the needs of the Ministry;*

## DECIDES

**Article 1.** To consider as ***temporarily closed*** the following factory of **Olympic Garment Co., Ltd.,** which was temporarily inactive for various reasons but whose production facilities, equipment and machinery are kept intact and whose workers were temporarily laid off.

This factory shall be de-registered from the GSP List of Eligible Exporters at the Trade Preferences Department. Its various quota allocations (if any) would be suspended. The eligibility of the said factory would be restored if it resumes its activities within the next three months, and its FY 2000 quota restored. If it was not resuming its activities in the next three months, its registration at the Ministry of Commerce's Commercial Register would be then struck in red and annotated as "closed".

**Article 2.** Further investigations shall be undertaken by the Trade Preferences Department, the Foreign Trade Department and the Legal Affairs Department regarding the liabilities and responsibilities of the above said company towards third parties in Cambodia as well as its liabilities vis-à-vis Cambodian laws and regulations.

**Article 3.** The Director of the Minister's Cabinet, the Technical Director General, the Director of the Trade Preferences Department, the Director of the Foreign Trade Department, the Director of the Legal Affairs department and the company whose name appears in Article 1 shall implement this Prakas from the date of its signing.

*The Minister of Commerce*

**CHAM PRASIDH**

CC:
Cabinet of H.E. Samdech Prime Minister
Cabinet of H.E. DPM & Co-Minister of Interior
Council of Ministers
Council for Development of Cambodia (CDC)
Ministry of Economy and Finance
Ministry of Industry, Mines and Energy
Ministry of Social Action, Labor, Vocational Training and Youth Rehabilitation
Royal Cambodian Embassy in Paris
Royal Cambodian Embassy in Washington DC
US Embassy in Phnom Penh
EU Delegation in Bangkok
Garment manufacturers Association in Cambodia
MOC Archives



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. 095 MoC / M 2002
*From the Minister's Desk*

**Phnom Penh, March 12, 2002**

## PRAKAS

### On The Status of Some Garment Factories in Cambodia

*****

## THE MINISTER OF COMMERCE

- *Pursuant to the Constitution of the Kingdom of Cambodia;*
- *Pursuant to the Preah Reach Kram No 02/NS/94 dated July 20, 1994 on the Organization and Functioning of the Council of Ministers;*
- *Pursuant to the Royal Decree No NS/RK/1198/72 dated November 30, 1998 on the Appointment of the Royal Government of Cambodia;*
- *Pursuant to the Preah Reach Kram No SN/RK/ 0196/16 dated January 24, 1996 on the Creation of the Ministry of Commerce;*
- *Pursuant to the Sub-Decree No 54 AK dated September 22, 1997 on the Organization and Functioning of the Ministry of Commerce;*
- *Seen the needs of the Ministry;*

## DECIDES

**Article 1.** To consider as ***definitely closed*** the followong garment factories which ceased to be operational and whose workers are laid off:

1- **Cheung Hing (Cambodia) Garment Knitting & Peal Embroidery Factory Co., Ltd.,**

2- **Elsimex Garment Co., Ltd**

3- **Bloomex (Cambodia) MFG Co., Ltd.**

These factories shall be de-registered from the GSP List of Eligible Exporters at the Trade Preferences Department. Their registrations at the Ministry of Commerce's Commercial Register shall be struck in red and annotated as "closed".

**Article 2.** Further investigations shall be undertaken by the Trade Preferences Department, the Foreign Trade Department and the Legal Affairs Department regarding the liabilities and responsibilities of the above said companies towards third parties in Cambodia as well as its liabilities vis-à-vis Cambodian laws and regulations.

**Article 3.** The Director of the Minister's Cabinet, the Technical Director General, the Director of the Trade Preferences Department, the Director of the Foreign Trade Department, the Director of the Legal Affairs department and the companies whose names appear in Article 1 shall implement this Prakas from the date of its signing.

*The Minister of Commerce*

**CHAM PRASIDH**

CC:
Cabinet of H.E. Samdech Prime Minister
Cabinet of H.E. DPM & Co-Minister of Interior
Cabinet of the Council of Ministers
Council for Development of Cambodia (CDC)
Ministry of Economy and Finance
Ministry of Industry, Mines and Energy
Ministry of Social Action, Labor, Vocational Training and Youth Rehabilitation
Royal Cambodian Embassy in Paris
Royal Cambodian Embassy in Washington DC
US Embassy in Phnom Penh
EU Delegation in Bangkok
Garment manufacturers Association in Cambodia
MOC Archives



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister' s Mobile Phone (855-12) 821888 Facsimile: (855-23) 213288
Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

ក្រសួងសាធារណការ
និង ដឹកជញ្ជូន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : 012 សក សជ ៣

រាជធានីភ្នំពេញ.ថ្ងៃទី 11 ខែ 03 ឆ្នាំ 2002

# សេចក្តីជូនដំណឹង

**យោង** :
- លិខិតលេខ ៣០២ សជណ.គម របស់ទីស្តីការគណៈរដ្ឋមន្ត្រីចុះថ្ងៃ ទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០២
- លិខិតប្រគល់ត្រាលេខ ០៣៨.២០០២ កគត ចុះថ្ងៃទី ០៦ ខែ មិនា ឆ្នាំ ២០០២ របស់ការិយាល័យគ្រប់គ្រងត្រានៃក្រសួងមហាផ្ទៃ ។

ក្រសួងសាធារណការ និង ដឹកជញ្ជូន សូមជំរាបជូនដំណឹងដល់គ្រប់ស្ថាប័ន ក្រសួង ខេត្ត-ក្រុង និង មន្ទីរ អោយបានជ្រាបថា រាជរដ្ឋាភិបាលបានសំរេច :

១. អនុញ្ញាតិអោយអគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និង ដឹកជញ្ជូន មានត្រាមូលសំរាប់ប្រើប្រាស់ក្នុងការងារជំនាញពាក់ព័ន្ធ នឹងវិស័យដឹកជញ្ជូនរបស់ខ្លួន ( ដូចមានជូនភ្ជាប់មកជាមួយនូវគំរូត្រា) ។

២. ប្រគល់សិទ្ធជូនអគ្គនាយក នៃអគ្គនាយកដ្ឋានដឹកជញ្ជូន ដើម្បីចុះហត្ថលេខាសំរេចលើឯកសារមធ្យោបាយយានយន្ត-ជលយានគ្រប់ប្រភេទ មានជាអាទិ:
- ប័ណ្ណសំគាល់យានយន្ត-ជលយាន
- លិខិតអាជីវកម្មដឹកជញ្ជូន
- ប័ណ្ណបើកបរ
- វិញ្ញាបនប័ត្រ
- សៀវភៅវិជ្ជាជីវៈនាវិក
- លិខិតអនុញ្ញាតិនាវាចូលកំពង់ផែ (Entry Permit) និង
- ឯកសារពាក់ព័ន្ធនឹងកិច្ចការដឹកជញ្ជូនដ៏ទៃទៀត សំរាប់ដោះស្រាយការងារប្រចាំថ្ងៃ ។

អាស្រ័យហេតុនេះ សូមគ្រប់ស្ថាប័ន ក្រសួង ខេត្ត-ក្រុង និង មន្ទីរ មេត្តាជ្រាប និង ទទួលស្គាល់ជាផ្លូវការ ចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

សំ-ស្មុខ

**ចំលងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ស្ថាប័ន ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ខេត្ត-ក្រុង
  " ដើម្បីជូនជ្រាប "
- គ្រប់អង្គភាពក្រោមឱវាទ
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

## គំរូត្រាមូលរបស់អគ្គនាយកដ្ឋានដឹកជញ្ជូន

( ឧបសម្ព័ន្ធលិខិតលេខ ០១២ សក.សជណ ចុះថ្ងៃ ទី ១១ ខែ មិនា ឆ្នាំ ២០០២ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន) ។

**គំរូត្រាមូល**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*****

**ក្រសួងអប់រំ យុវជន និង កីឡា**

លេខ......៧៤៧......អយក.ប្រក

# ប្រកាស

*******

ស្តីពីការបើកវិទ្យាល័យ « កំពង់ឈើទាល ស្រុកប្រាសាទសំបូរ »

ស្ថិតក្នុងឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨_៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម លេខ ០២ នស_៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រម នស_រកម ០១៩៦_០១ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា។
- បានឃើញព្រះរាជក្រឹត្យ លេខ នស_រកត ០៧៩៦_៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ ។
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ_បក ចុះថ្ងៃទី ២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា ។
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទមចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១_កំរិត២។
- យោងលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និងកីឡា លេខ ១៥៨៩ អយក.កធ.រប ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០១ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តកំពង់ធំ ។
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ។

## សំរេច

**ប្រការ ១ :** អនុញ្ញាតអោយបើកវិទ្យាល័យដែលមានឈ្មោះថា : វិទ្យាល័យ « កំពង់ឈើទាល ស្រុកប្រាសាទសំបូរ » ស្ថិតនៅក្នុងឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២ :** វិទ្យាល័យនេះផ្តល់ពុទ្ធិទូទៅនៅកំរិតមធ្យមសិក្សាបឋមភូមិ និងពុទ្ធិទូទៅផង វិជ្ជាជីវៈផងនៅកំរិតមធ្យមសិក្សាទុតិយភូមិ ។

**ប្រការ ៣ :** វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃវិទ្យាល័យ ។

**ប្រការ ៤ :** នាយក_នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៥ :** អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំយុវជននិងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ធំ និង នាយកវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ , ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០២

**ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា**

**រដ្ឋលេខាធិការ**

**អ៊ឹម_សិទ្ធី**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តកំពង់ធំ " ដើម្បីជាពត៌មាន "
- ដូចប្រការ ៥
- កាលប្បវត្តិ_ឯកសារ នា.មចទ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងធម្មការ និង សាសនា**

លេខ...៧៦......ក.ធ.ស

# សេចក្តីសំរេច

ស្តីពីការអនុញ្ញាតឱ្យកសាងព្រះវិហារថ្មី ដែលស្ថិតនៅក្នុង" វត្តចំប៉ីមុនីរតនារាម "
នៃគណៈមហានិកាយ ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ

## រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.

-បានឃើញព្រះរាជក្រមលេខ នស.រកម០១៩៦-១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា.

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា.

-យោងតាមចំណេះយោបល់ករបស់អភិបាល ខេត្ត តាកែវ លេខ ៣៧៣បជ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ២០០១.

-យោងតាមចំណាររបស់ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តតាកែវ លេខ ៣២៩/ ០១ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០១.

-យោងតាមចំណាររបស់អភិបាលស្រុកបាទី លេខ៦០២ សប ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១.

-តាមសំណើសុំកសាងព្រះវិហារថ្មីរបស់គណៈកម្មការ អាចារ្យ ដែលស្ថិតនៅក្នុងវត្ត ចំប៉ីមុនីរតនារាម ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ឆ្នាំ ២០០១.

## សំរេច

**ប្រការមួយ:** អនុញ្ញាតឱ្យក សាង ព្រះវិហារថ្មី ដែលស្ថិតនៅក្នុង" វត្ត ចំប៉ីមុនីរតនារាម " នៃគណៈមហានិកាយ ឃុំ ចំបក់ ស្រុកបាទី ខេត្តតាកែវ ដោយរក្សានូវក្បាច់រចនា ជាប្រពៃណីរបស់ជាតិ ។

**ប្រការពីរ :** ព្រះវិហារថ្មីនេះ ត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបានត្រឹមត្រូវ តាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត និងប្រពៃណីពុទ្ធសាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបាន ល្អប្រសើរ និងរីកចំរើន ។

**ប្រការបី :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្ម ការ និងសាសនា ខេត្តតាកែវ អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអាចារ្យ- គណៈកម្មការវត្ត ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថ - លេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែ ០២ ឆ្នាំ ២០០២

**ចម្លងជូន :**

-សម្តេចព្រះសង្ឃរាជគណៈមហានិកាយ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
" ដើម្បីថ្វាយ-ជូនជ្រាប "
-រាជកិច្ច " ដើម្បីចុះផ្សាយ "
-សាលាខេត្តតាកែវ
-អភិបាលស្រុកបាទី
-ដូចប្រការបី
" ដើម្បីសហការអនុវត្ត "
ឯកសារ-កាលប្បវត្ត

ជា_សាវឿន

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា

លេខ..៧៥៧....ក.ធ.ស

# សេចក្តីសំរេច

ស្តីពីការអនុញ្ញាតឱ្យកសាងព្រះវិហារថ្មី ដែលស្ថិតនៅក្នុង" វត្តទេពបូរី "
នៃគណៈមហានិកាយ ឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ

## រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា.

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី.

-បានឃើញព្រះរាជក្រមលេខ នស.រកម០១៩៦-១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា.

-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងធម្មការ និងសាសនា.

-យោងតាមចំណារឯកភាពរបស់អភិបាល ខេត្ត តាកែវ លេខ ៤០៤សបជ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០០១.

-យោងតាមចំណាររបស់ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តតាកែវ លេខ ៣៤១បធសតក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១.

-យោងតាមចំណាររបស់អភិបាលស្រុកបាទី លេខ៦៣២ សប ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០១.

-តាមសំណើសុំកសាងព្រះវិហារថ្មីរបស់គណៈកម្មការ អាចារ្យ ដែលស្ថិតនៅក្នុងវត្ត ទេពបូរី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០១.

## សំ រេ ច

**ប្រការមួយ:** អនុញ្ញាតឱ្យកសាង ព្រះវិហារថ្មី ដែលស្ថិតនៅក្នុង " វត្តទេពបូរី " នៃគណៈមហានិកាយ ឃុំ ក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ ដោយរក្សានូវក្បាច់រចនា ជាប្រពៃណីរបស់ជាតិ ។

**ប្រការពីរ :** ព្រះវិហារថ្មីនេះ ត្រូវដាក់ប្រគេនព្រះសង្ឃ និងជូនពុទ្ធបរិស័ទគោរពប្រតិបត្តិ និងធ្វើបុណ្យទានឱ្យបានត្រឹមត្រូវ តាមពុទ្ធប្បញ្ញត្តិ និងពុទ្ធានុញ្ញាត និងប្រពៃណីពុទ្ធសាសនា ព្រមទាំងច្បាប់របស់រដ្ឋឱ្យបាន ល្អប្រសើរ និងរីកចំរើន ។

**ប្រការបី :** ខុទ្ទកាល័យ អគ្គនាយកដ្ឋានធម្មការ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរធម្មការ និងសាសនា ខេត្តតាកែវ អង្គភាពពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ និងអាចារ្យ- គណៈកម្មការវត្ត ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៤ ខែមិនា ឆ្នាំ ២០០២

រដ្ឋមន្ត្រី

ជា_សាវឿន

**ចម្លងជូន:**

-សម្តេចព្រះសង្ឃរាជគណៈមហានិកាយ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
" ដើម្បីថ្វាយ-ជូនជ្រាប "
-រាជកិច្ច " ដើម្បីចុះផ្សាយ "
-សាលាខេត្តតាកែវ
-អភិបាលស្រុកបាទី
-ដូចប្រការបី
" ដើម្បីសហការអនុវត្ត "
ឯកសារ-កាលប្បវត្ត